# ដំណើររត់ចេញពីឋាននរកមករកប្រទេសថៃ

នៅស្រុកព្រៃកប្បាស ខេត្តតាកែវ នៅក្នុងឆ្នាំ១៩៧៥
ពុំសូវមានភ្លៀងធ្លាក់គ្រប់គ្រាន់ទេការធ្វើស្រែមានការយឺតយ៉ាវខ្លាំងណាស់
ដោយសារតែរង់ចាំទឹកភ្លៀង ពេលខ្លះស្ទូងគោករង់ចាំទឹកភ្លៀង។
យើងបានដកស្ទូងរួចរាល់ហើយរហូតមកដល់ពាក់កណ្តាលខែ១១ឯណោះ។
នៅខេត្តខ្លះស្រូវគេដាក់គ្រាប់ជិតទុំអស់ទៅហើយ។
បន្ទាប់ពីបានដកស្ទូងរួចរាល់អស់ហើយ នៅពាក់កណ្តាលខែ១១ឆ្នាំ១៩៧៥ ពួកអ្នកជំលៀសចេញពីក្រុងភ្នំពេញ គេហៅថាពួកប្រជាជនថ្មី
ដែលបានវិលមករស់នៅឯស្រុកកំណើត នៅឯស្រុកព្រៃកប្បាស ស្រុកសំរោង និង ស្រុកបាទី ខេត្តតាកែវ ត្រូវបានពួកខ្មែរក្រហម ជូនដំណឹងមកថា
គេត្រូវជំលៀសពួកប្រជាជនថ្មី ឲ្យទៅរស់នៅឯខេត្តបាត់ដំបងវិញ។
ម្នាក់ៗមានសេចក្តីសប្បាយរីករាយណាស់ ដោយសង្ឃឹមថានឹងបានបាយហូបឆ្អែត
ហើយមានលទ្ធភាពអាចរត់មកស្រុកសៀមបានកាន់តែជិតទៀតផង។
នៅខ្ទង់ថ្ងៃទី១៨ខែ១១ឆ្នាំ១៩៧៥ ពួកយើងត្រូវដើរចម្ងាយដី ប្រហែលជា៣០គម ឬក៏ជាង៣០-៥០គម មកកាន់ចំណតរថភ្លើង នៅរ៉ាកុមាររាជា
នៅខាងកើតផ្សារត្រាំខ្នាប្រ ហែលជា៦គម និង នៅខាងលិចផ្សារសំរោងយ៉ោង ប្រហែលជា៨គម។ ពួកយើងបានចេញដំណើរតាំងតែពីម៉ោង៥ព្រឹក
មកដល់គោលដៅនៅខ្ទង់ម៉ោង៨-៩យប់។ ពួកចាស់ ៗ និង ពួកអ្នកមានជម្ងឺដើរមិនរួច គេឲ្យជិះរទេះគោ។
យើងបានមកដេកចាំនៅរ៉ាកុមាររាជានេះអស់៤យប់
ទើបបានឃើញមានរទេះភ្លើងមកដឹក។ នៅពេលនោះជាខែរងារខ្លាំងខុសឆ្នាំធម្មតា ធ្វើឲ្យមនុស្សចាស់ និង កូនក្មេងងាយនឹងឈឺ ដោយសារធាតុអាកាសត្រជាក់ផង និង ការខ្វះម្ហូបអាហារមិនគ្រប់គ្រាន់ផង។ពួកយើងបានដេកនៅតាមផ្លូវអស់១យប់
នៅម្តុំរ៉ាទ័ទឹងថ្ងៃ ក្នុងខេត្តពោធិសត្វ។ នៅម៉ោ ង៤រសៀល
រទេះភ្លើងបាននាំពួកយើងមកដល់ រ៉ាទីក្រុងសេរីសោភ័ណ្ឌ។ មកដល់ទី នេះ
ខ្ញុំមានសេចក្តីត្រេកអរក្នុងចិត្តរកអ្វីប្រៀបពុំបានឡើយ
ពីព្រោះនៅពេលនោះបន្ទាប់ពីខ្ញុំបានវិលមករស់នៅ
លត់ដំឯស្រុកកំណើតបាន៦-៧ខែមក ខ្ញុំមានការអស់សង្ឃឹមក្នុងខ្លួនរលីងធេង
ដោយចេះតែគិតថាអនាគតរបស់ខ្ញុំ និង ខ្មែរដ៏ទៃទៀតត្រូវតែសាបសូន្យ
ដោយសារការដែលខ្ញុំខំតស៊ូរៀនសូត្រ លះបង់ការសប្បាយអស់ចំនួន១៦ឆ្នាំមកនេះ
ត្រូវរលាយដូចអំបិលត្រូវទឹក ដូចក្រមួនត្រូវថ្ងៃ។ សេចក្តីសង្ឃឹមរបស់ខ្ញុំនិងរបស់គ្រួ សារ
បានដើរមកដល់ទីបញ្ចប់ នៅក្នុងរបបដ៏ព្រៃផ្សៃនេះ អស់រលីងហើយ។
នៅខែ៦-៧ឆ្នាំ១៩៧៥ ខ្ញុំត្រូវប្រឡងបញ្ចប់ការសិក្សារបស់ខ្ញុំ
ថ្នាក់បរិញ្ញាបត្រផ្នែកពាណិជ្ជសាស្រ្ត និង បរិញ្ញាបត្រខាងច្បាប់សេដ្ឋកិច្ច License de Commerce et License de Droit Econimic ( Bachelor Degree of Business and Law Economic ) ក្នុងអាយុទើបតែបាន២៣ឆ្នាំ។
ខ្ញុំគិតថាខ្ញុំអាចមានអនាគតវែងឆ្ងាយទៅមុខទៀត ខ្ញុំអាចរៀនបន្តបានថែមទៀត និង អាចធ្វើការងារបានធំដុំគ្រាន់បើនឹងគេ អាចមានអនាគតដ៏ភ្លឺថ្លាជាមិនខានឡើយ
ហើយខ្ញុំក៏អាចជួយយិតយោងក្រុមគ្រួសារយើងបងប្អូនយើង អ្នកស្រុកយើង

បានវែងឆ្ងាយតទៅទៀតបានផងដែរ។ តែអនិច្ចារក្នុងលោ កយើងនេះ
អ្វីៗសុទ្ធតែមិនទៀងទាត់សោះឡើយ
នៅពេលពួកខ្មែរក្រហមចូលមកដល់អ្វីៗត្រូវបានប្រែប្រួល១០០%
ការកាប់សម្លាប់មនុស្ស ការជំលៀសមនុស្សពីកន្លែងមួយទៅកន្លែងមួយទៀត
ទុរភិក្សកើតឡើងពេញប្រទេស ធ្វើឲ្យជីវិតខ្ញុំក្លាយទៅជាមនុស្សឆ្កួ
តពាក់កណ្ដាលបាត់ទៅហើយ។ កាលណោះខ្ញុំបានគិតថា
ខ្ញុំត្រូវតែចេញឲ្យផុតអំពីផែនដីដ៏អប្រិយ៍ និង អំពីរបបដ៏ព្រៃផ្សៃនេះ
ទោះបីជាខ្ញុំត្រូវស្លាប់ខ្លួន វាល្អជាងការរស់នៅជា មួយមនុស្សព្រៃផ្សៃបែបនេះ។
ខ្ញុំបានប្រាប់អាផាវជីដូនមួយខ្ញុំថា មិនយូរទេខ្ញុំត្រូវតែរត់ទៅហើយ យ៉ាងយូរណាស់ខ្ញុំអា
ចដើរចំនួនតែ២ខែទេ នឹងបានទៅដល់ស្រុកសៀមហើយ។ ជីដូនមួយខ្ញុំក៏យល់ព្រមហើ
យវាក៏បានពិភាក្សាជាមួយមាខ្ញុំ(គួលាន)អំពីផែនការរត់នេះដែរ
គឺរត់ពីតាកែវទៅស្រុកសៀម។ សំណាងល្អនៅពេលនោះ
ជួនជាពេលដែលពួកខ្មែរក្រហម មានផែនការចង់ជំលៀសពួកយើង
ឲ្យមករស់នៅឯខាងខេត្តបាត់ដំបងវិញ
ហាក់ដូចជាជួនដំណើរពួកយើងឲ្យមកកាន់តែជិតទល់ដែនសៀមទៅវិញ។
នៅពេលចុះពីរទេះភ្លើង នៅសេរីសោភ័ណ្ឌ ខ្ទង់ថ្ងៃទី២២ខែ១១ឆ្នាំ១៩៧៥
ខ្ញុំពីរនាក់អាចាន់ថា(កូនលោកគ្រូហៀក) ក៏បានចុះឈ្មោះចូល
នៅក្នុងក្រុមកងចល័តដាច់ខាតភ្លាមពីព្រោះគិតថា យើងមកដល់កាន់តែកៀកហើយ
មិនគួរនឹងប្រញាប់ស្រូតរត់ភ្លាមៗនោះទេ
ត្រូវពិនិត្យមើលស្ថានការណ៍ឲ្យបានច្បាស់លាស់ជាមុនសិន។
ពួកក្រុមកងចល័តដាច់ខាតនេះ ត្រូវចល័តឲ្យទៅធ្វើការនៅគ្រប់ទីកន្លែង
ដែលជាឱកាសនាំឲ្យយើងបានស្គាល់ភូមិសាស្ត្រ
ខេត្តបាត់ដំបងកាន់តែច្បាស់ថែមទៀត។ នៅពេលបែកចេញពីម៉ែឪបងប្អូនមក
ខ្ញុំក៏គ្មានពាក្យអ្វីនឹងនិយាយលាពួកគាត់ទេ
តែចិត្តខ្ញុំសែនក្ដុកក្ដួលពេកក្រៃរកនិយាយអ្វីក៏ពុំចេញសោះ។
ខ្ញុំក៏បានទៅលាកុងអឿង(កុងខ្ញុំខាងម្ដាយ) គាត់អាយុខ្ទង់៨០ឆ្នាំហើយ
គាត់បានបង្រៀនខ្ញុំឲ្យចេះអាន ចេះសរសេរតាំងតែពីខ្ញុំអាយុបាន៤-៥ឆ្នាំមកម៉្លេះ
ខ្ញុំស្រឡាញ់នឹងគោរពគាត់ណាស់ គាត់បានអប់រំខ្ញុំតាំងតែពីតូចមកឲ្យខ្ញុំចេះដឹងខុសត្រូវ
ក្លាយជាក្មេងល្អ សិស្សល្អទៅអនាគត។ គុណូបការៈរបស់គាត់ចំពោះខ្ញុំ
មានទំហំធំធេងណាស់ ដែលខ្ញុំមិនទាន់ដែលមានឱកាស
បានសងគុណគាត់ម្ដងណានៅឡើ យទេ។ គាត់អាណិតស្រឡាញ់ខ្ញុំជាងគេ។
ខ្ញុំអួលណែនដើមទ្រូងរកនិយាយអ្វីក៏មិនចេញ បានត្រឹមតែថាចៅសុំលាកុងសិនហើយ
ទៅចូលកងចល័តដាច់ខាត បើជីវិតចៅនៅមាន យើងគង់តែបានជួបគ្នាវិញទេ
ហើយគាត់ក៏បានជូនពរដល់ខ្ញុំសូមទៅឲ្យបានសុខចុះ។
បន្ទាប់ពីបានដើរនៅក្នុងកងចល័តដាច់ខាតនេះបាន៤-៥ខែមក
នៅខែមេសាចូលឆ្នាំខ្មែរឆ្នាំ១៩៧៦ ខ្ញុំមានគ្នា៣នាក់: 1- អាចាន់ថា(កូនលោកគ្រូហៀក)
និង 2- អាបូណា(កូនលោកគ្រូសួរ) គេបានបើកឲ្យពួកកងចល័ត
វិលទៅរកឪពុកម្ដាយវិញ នោះពួកយើ ងក៏មិនបានដឹងថា ឪពុកម្ដាយបងប្អូន
ត្រូវគេជំលៀសទៅដល់ទីណាភូមិស្រុកណាទេ។ពួកយើងក៏សំរេចចិត្តដើរទៅទិសខាង

ជើង ដើម្បីឲ្យបានទៅជិតព្រំដែន ដើម្បីសុំគេរស់នៅភូមិណា
ដែលថិតនៅចុងគេបង្អស់។
ដើរបាន១ថ្ងៃ ក៏ត្រូវពួកខ្មែរក្រហមចាប់បាន នៅឯខាងស្រុកភ្នំស្រុក តែនៅពេលនោះវា
រកមិនឃើញមានភស្តុតាងអ្វី ថាពួកយើងជាពួកចង់រត់មកស្រុកសៀមទេ។
យើងបានប្រាប់វាថា យើងដើររកម៉ែឪ មិនដឹងនៅទីណាទេ
វាក៏ចាប់ឲ្យពួកយើងជួយធ្វើការជាមួយគេ នៅក្បែរៗនោះទៅ
ឯអាប្អូនណាវិញក៏បានរត់ថយក្រោយបាត់ទៅ។
យើងក៏បានស៊ើបសួររកអ្នកធ្វើការជាមួយគ្នា
ដែលមកពីស្រុកឆ្ងាយៗនៅខាងខេត្តឧត្តរមានជ័យ ជិតទល់ដែន នៅទីបំផុត
ក៏មានស្គាល់ក្មេងម្នាក់ អាយុស្រករៗគ្នាដែរ
ក៏សុំវាធ្វើជាក្លើម្រាក់ទៅ។នៅពេលចប់ការងារនៅទីនេះ គេក៏បញ្ជូនពួកយើងនេះ
ឲ្យវិលទៅស្រុកភូមិវិញ។ ពួកយើងក៏សុំទៅភូមិជាមួយក្លើម្រាក់ថ្មីនេះ។
នៅពេលមកដល់ភូមិ គឺភូមិកន្ទួត ឃុំណាំតាវស្រុកភ្នំស្រុក
ដែលជាឃុំចុងខាងជើងគេបំផុត មានព្រំដែនជាប់នឹងស្រុកចុងកាល
ខេត្តឧត្តរមានជ័យ។ យើងក៏បានចូលទៅសុំប្រធានភូមិ រស់នៅទីនេះរហូតមក
ដោយបានប្រាប់គេថា បានបែកពីម៉ែឪ តាំងតែពេលចុះពីរទេះភ្លើង
ចូលកងចល័តដាច់ខាតមកម្លេះមិនដឹងជាពួកគាត់ ត្រូវគេបញ្ជូនទៅខាងណាទេ។
រស់នៅក្នុងភូមិយើងបានធ្វើឲ្យប្រជាជន និងប្រធានភូមិ ស្រឡាញ់ចូលចិត្តយើងខ្លាំង
ពីព្រោះយើងធ្វើការងារយ៉ាងសកម្មទាំងយប់ទាំងថ្ងៃ មិនសូវហ៊ានសំរាកទេ។
យើងអាចលីបាវស្រូវ បាវអង្ករ បានដោយស្រួល។ ក្រោយមកគេបានចាត់តាំងឲ្យខ្ញុំ
ជាអ្នកចែកអង្ករ ឲ្យប្រជាជនទៀតផង ដូច្នេះរឿងស៊ីចុក មិនសូវជាចោទទេ។
យើងបានមករស់នៅក្នុងភូមិកន្ទួតនេះ
បានជាង១ឆ្នាំហើយយើងបានឌឺស្រាវជ្រាវភូមិសាស្រ្ត នៅក្នុងតំបន់នេះ និង
នៅខាងទល់ដែន និង នៅតំបន់ព្រៃទៅទល់ដែន បានយ៉ាងល្អិត។
នៅដើមឆ្នាំ១៩៧៧ អាចាន់ថា ត្រូវគេចាត់វាឲ្យទៅលើកទំនប់
នៅឯអាងត្រពាំងថ្ម(ទំនប់ធំជាងគេនៅក្នុងស្រុកខ្មែរយើង)
វាបានជួបបងប្អូនខ្លះៗមកពីខាងព្រះនេត្រព្រះដែរ។
ដល់ពេលវាត្រឡប់មកដល់ភូមិវិញ វាបានឲ្យដំណឹងមកប្រាប់ខ្ញុំថា ឪពុកម្តាយនិងកុង
និងម្តាយធំ ខាងឪពុកខ្ញុំ២នាក់ ក៏បានស្លាប់បាត់អស់ទៅហើយ
នៅឯស្រុកព្រះនេត្រព្រះ។ វាបានជួបហ៊ាជាប (បងប្រុសទី២របស់ខ្ញុំ)
នៅលើខ្នងទំនប់អាងត្រពាំងថ្មនេះ ក៏បានដឹងនូវរឿងរ៉ាវសព្វគ្រប់។
ហ៊ាជាបត្រូវប្រធានកងទាត់៣-៤ជើងដោយសារតែរវល់មកនិយាយសារសងគ្នាយូរពេក
។ ខ្ញុំហួសបើនឹងគិតបន្ទាប់ពីបានទទួលដំណឹងមិនល្អអំពីក្រុមគ្រួសារខ្ញុំនេះមក។
យើងបានគិតថាមិនត្រូវបន្តធ្វើឲ្យខាតពេលយូរតទៅទៀតឡើយ។ នៅទីបំផុត
យើងបានត្រៀមលក្ខណៈ ធ្វើត្រីស៊ុយបាន២គ្រឿង កាំមែលដាក់ទឹក
និងស្បៀងអាហារខ្លះៗ ទុកសំរាប់រត់ទៅសៀម។ នៅខែ១២ឆ្នាំ១៩៧៧
ពួកយើង២នាក់ ក៏សំរេចចិត្តរត់ទាំងយប់ ដើរកាត់ព្រៃ កាត់ដុំប កាត់វាលស្រែ
ប្លន់ស្រូវនៅតាមផ្លូវដាក់ហោប៉ៅ ទុកធ្វើជាស្បៀងបន្តទៅមុខទៀត។
យើងដើរភាគច្រើននៅពេលយប់ និងនៅពេលខែលិច អស់រយៈពេល៣យប់៣ថ្ងៃ

ដើរកាត់តែព្រៃ ពួកយើងក៏ដាច់ទឹកនៅកណ្តាលថ្ងៃក្តៅ ធ្វើឲ្យយើងក្រហល់ក្រហាយ
ពិបាកទ្រាំស្ទើងតែមិនបានពួកយើ ងលែងខ្លាចងាប់ ក៏សំរេចចិត្តដើរកភូមិ
ចូលទៅរកទឹកផឹក។ យើងក៏បានទៅដល់ភូមិរហោឋានមួយ
ដែលគេបានបោះបង់ចោល គ្មានមនុស្សរស់នៅសោះ។
យើងក៏បានចុះទៅត្រាំទឹកក្នុងស្រះមួយយ៉ាងសប្បាយ។
យើងដើរបាន៤យប់៥ថ្ងៃហើយ យើងឡើងលើដើមឈើរកមើលភ្នំវែងៗ (ភ្នំដងរែក)
តែរកមើលមិនឃើញសោះ ពីព្រោះវាបាំងព្រៃមើលមិនឃើញ។
ខ្ញុំមានការអស់សង្ឃឹមបន្តិចដែរ ដោយដើរបាន៤-៥ថ្ងៃហើយ
នៅតែរកមើលភ្នំដងរែកមិនឃើញទៀត ហើយក៏គិតថាប្រហែលជាវង្វេងទេដឹង
តែយើងបានប្រើត្រីវិស័យ២គ្រឿង ជាជំនួយ ដើម្បីកុំឲ្យយើងដើរខុសទិស។
យើងបានគិតប្រមានថាដើរតែ៣-៤ថ្ងៃ ប្រាកដជាទៅដល់ទល់ដែនសៀមហើយ។
នៅពេលណាមេឃស្រឡះ យើងអាចមើលពីភូមិទៅ ឃើញភ្នំដងរែកច្បាស់គួរសមដែរ
តាមពិតទៅ ពួកយើងបានដើរមកនេះ ត្រូវទិសល្អណាស់ តែដោយសារតែយើងដើរវៀ
ងភូមិអ្នកស្រុកផង ដើរវៀងទំបន់ទឹកផង ដើរកាច់កុងចុះឡើង ធ្វើឲ្យស៊ីពេលយូរបន្តិច។
យើងបានដើរកាត់មករកស្រុកថ្មពួក នៅម្តុំស្រុកគោកមន ឋិតនៅក្នុងខេត្តឧត្តរមានជ័យ
កាត់មកតាមម្តុំភូមិពងទឹក ឡើងមករកខាងភូមិបាក់រនាស់
ចូលទៅស្រុកឋានត្រួត(ស្រុកគ្រួស) ក្នុងខេត្តបូរីរាំ ប្រទេសថៃ។ ដើរបានមួយព្រឹកទៀត
យើងក៏បានឃើញភ្នំវែងអន្លា យនៅនឹងមុខយើងសោះ
គួរឲ្យស្រណោះជាពន់ពេកណាស់។
យើងក៏បានដើរតម្រង់ទៅរកកំពូលភ្នំណាដែលខ្ពស់ជាងគេ ដោយគិតឃើញថា
ទីនោះប្រហែលជាពួកខ្មែរក្រ ហម មិនសូវឃាមកាមប្រយ័ត្នប៉ុន្មានទេមើលទៅ។
នៅតាមផ្លូវពួកយើងក៏បានជួបជាមួយពួកខ្មែរក្រហមខ្លះៗដែរ
តែនៅពេលយប់ពួកវាមើលពួកយើងមិនឃើញទេ។ យើងបានជួបឃើញជំរូង
ឬក៏អង្គប់ជាច្រើនកន្លែង នៅតាមផ្លូវព្រៃ ចូលកៀកៗមកជិះព្រំដែនភ្នំដងរែក។
ពួកយើងដើរក្នុងព្រៃលើ បានជួបនឹងសត្វជាច្រើនប្រភេទ ជាពិសេសហ្វូងជ្រូកព្រៃ ហើ
យមានព្រឹកមួយនោះ បានឃើញខ្លាដេញហ្វូងជ្រូកព្រៃទៀតផងដែរ។
យើងបានដើរកាត់កូនភ្នំតូចៗ
បានឃើញមានស្នាមជើងឈ្លូសនៅជាប់លើផ្ទាំងថ្មរាប់លានឆ្នាំមកហើយ។
គិតទៅបើកុំតែស្រុកយើងពិបាកវេទនាយ៉ាងនេះ ក៏អីការដើរលេងនៅក្នុងព្រៃរបៀ បនេះ
វាអាចក្លាយទៅជាការដើរកំសាន្ត Promenade យ៉ាងសប្បាយទៅវិញទេ ពី
ព្រោះវាជាការដើរផ្សងព្រេង នៅក្នុងធម្មជាតិ យើងអាចក្រេបរស់ជាតិ
អំពីសម្រស់ព្រៃភ្នំយើងអាចគួយគន់មើល សត្វព្រៃគ្រប់ប្រភេទបានទៀតផង។
យើងបានគិតដូច្នេះទៅការធ្វើដំណើររបស់យើង
ហាក់ដូចជាមិនសូវជាហត់នឿយប៉ុន្មានទេ។ យើងដើរបាន៦ថ្ងៃ
យើងហត់នឿយអស់កម្លាំងមែនទែនហើយ។ យើងដើរបាន៣00ម
ត្រូវឈប់ម្តងពីព្រោះទន់ជង្គង់ដើរទៅមុខលែងចង់រួចទៀតហើយ
តែលុះបានឃើញជួរភ្នំដងរែកកាលណា យើងក៏មានកម្លាំងព្រឺសុទ្ធឡើងវិញភ្លាម។
នៅពេលនោះយើងមិនសូវជាប្រញាប់ប៉ុន្មានទេ ពីព្រោះខ្លាចដល់កំពង់លង់ទូក
ដូចពាក្យចាស់និយាយអញ្ចឹង គឺយើងត្រូវតែប្រយ័ត្នប្រយែងជាងមុន។

ពួកយើងបានសម្ងំនៅក្នុងព្រៃដុបមួយ
ដើម្បីរង់ចាំមើលសកម្មភាពយាមល្បាតរបស់ពួកខ្មែរក្រហម
នៅតាមជើងភ្នំជិតទល់ដែនថៃនេះ។
យើងអង្គុយចាំរហូតដល់ថ្ងៃលិចទើបយើងហ៊ានរត់ឡើងទៅលើភ្នំតែម្តង។
យើងរត់ផ្លោះកាត់រណ្តៅជុំរួង
រត់កាត់ចំការមីនរួចហើយក៏បានឆ្លងមកដល់ជើងភ្នំតែម្តង។ ភ្នំដងរែកនេះ
មិនសូវជាខ្ពស់ប៉ុន្មានទេ យើងបានខំប្រឹងឡើងទៅដល់កំពូលភ្នំ
ត្រូវស៊ីពេលអស់ប្រហែលជា៥ម៉ោង យើងបានមកដល់កំពូលភ្នំ នៅម៉ោង១២អធ្រាត។
យើងបានដើរនៅលើកំពូលខ្នងភ្នំ ហើយក៏បានដើរចុះក្រោមបន្តិច
ហើយក៏នឹកក្នុងចិត្តថា
ពួកយើងប្រាកដជាបានចូលមកដល់ដីថៃហើយដោយចេះតែគិតថាព្រំដែនខ្មែរ-ថៃគឺខ័
ណ្ឌចែកគ្នានៅលើកំពូលភ្នំដងរែក
តាមពិតទៅព្រំដែននេះត្រូវឋិតនៅជើងភ្នំម្ខាងទៀតឯណោះទេ
គឺត្រូវដើរជិតមួយថ្ងៃចុះក្រោមទៅជើងភ្នំម្ខាងទៀត
ទើបបានទៅដល់ព្រំដែនពិតរបស់វា។ ពួកយើងត្រេកអរណាស់
ដោយនឹកស្មានថាបានមកដល់ដីថៃហើយ ចង់ស្រែកច្រៀងសក្តក្រវា
ឲ្យបានសប្បាយធូរចិត្តទៅ
ហើយនឹកគិតថាថ្ងៃស្អែក អញនឹងបានទៅស៊ីគុយទាវ នៅដីថៃហើយ
តែតាមពិតទៅនៅក្នុងខ្លួន ពុំមានលុយមួយកាក់មួយសេនសោះឡើយ។
យើងក៏បានដុតភ្លក់ភ្លើងច្រៀងយ៉ាងរំភើយ តែតាមពិតទៅត្រង់កន្លែងនោះ
វាឋិតនៅក្នុងទឹកដីខ្មែរយើងនៅឡើយទេ ពីព្រោះព្រំដែនខ្មែរ-ថៃ វាឋិតនៅចូលទៅជ្រៅ
រហូតដល់ទៅជាងពាក់កណ្តាលចង្កេះភ្នំជិតដល់ជើងភ្នំម្ខាងទៀតឯណោះទេ។
លុះក្រោយមកទើបបានដឹងច្បាស់ អំពីរឿងព្រំដែននេះ
ទើបបានភ័យខ្លួនជាក្រោយវិញ។ តែសំណាងល្អ អាយុមិនអស់ ទឹកដោះម្តាយថ្លៃ
ក៏ចេះតែរស់បាន ឆ្លងកាត់គ្រប់ឱបសគ្គបាន ដោយជោគជ័យ។
យើងបានដើរចុះភ្នំ១យប់១ថ្ងៃទៀត ទើបបានមកដល់ភូមិថៃ ហើយគេក៏បាននាំពួកយើ
ងទាំង២នាក់ ទៅជួបពួកតំរួត(ប៉ូលីស)ជាយដែន
នៅស្រុកបានគ្រួត(ខ្មែរហៅថាស្រុកគ្រួស)
ឋិតនៅក្នុងខេត្តបុររាំ(នៅខាងលិចជាប់នឹងខេត្តសុរិន្ទ)។
នៅស្រុកនេះមានប្រជាជនថៃចេះនិយាយភាសាខ្មែរបានសឹងតែ៨០%-៩០%។
ពួកតម្រួតជាយដែនបានសាក សួរយើងយ៉ាងយូរ គេចង់ដឹងថាយើងជាពួកខ្មែរក្រហម
ឬក៏មិនមែន បើជាពួកខ្មែរក្រហ ម គេនឹងយកទៅសម្លាប់ចោលភ្លាម
ពីព្រោះពួកខ្មែរក្រហម និ ងពួកសៀមក្រហម តែងតែសហការគ្នា
ធ្វើការវាយលុកនៅតាមប៉ុស្តិ៍ព្រំដែនជាញឹកញយ ហើយបានសម្លាប់ប្រជាជនថៃ
ដែលរស់នៅតាមព្រំដែន ដុតផ្ទះអ្នកស្រុក ដុតប៉ុស្តិ៍ប៉ូលីសជាដើម។
នៅក្នុងចន្លោះខែ១ដល់ខែ១២ឆ្នាំ១៩៧៧នេះ
ខ្មែរយើងភាគច្រើនដែលបានរត់មកដល់ប្រ ទេសថៃហើយ
ត្រូវពួកថៃសម្លាប់ចោលស្ទើគ្មានសល់ ដើម្បីជាការសងសឹង
ទៅនឹងពួកខ្មែរក្រហម-សៀមក្រហម ដែលចេះតែមកអុកឡុកនៅទល់ដែនថៃនេះ។

ដូច្នេះចំពោះបងប្អូនណាដែលមានសាច់ញាតិ រត់ចូលមកស្រុកថៃ
នៅក្នុងកំឡុងពេលនេះ ពុំសូវមានសំណាងបាននៅរស់ទេ។ គួរឲ្យអនិច្ចាណាស់
ដែលខំតស៊ូរត់ចេញអំពីរបបខ្មែរក្រ ហមបានយ៉ាងវេទនា
នៅទីផុតត្រូវពួកសៀមយកទៅសម្លាប់ចោលទៀត។
ឱខ្មែរយើងអើយម្តេចឡើយអ្នកក៏រងកម្មអីខ្លាំងម្លេះ តើពួកអ្នកបានធ្វើបុណ្យអីខ្លះទៅ
បានជាវេទនាជាងគេអញ្ចឹង?
នៅទីបំផុតពួកតំរួតថៃ បានជឿថាពួកយើងមិនមែនជាពួកខ្មែរក្រហមទេ
វាបានឃើញត្រីវិស័យរបស់យើង២គ្រឿង ដែលយើងបានធ្វើដោយផ្ទាល់ដៃ
ពួកតំរួតវានាំគ្នាសើច។
បន្ទាប់ពីពួកតំរួតជាយដែនបានសួរចម្លើយសព្វគ្រប់រួចហើយ
គេក៏ឲ្យពួកយើងរស់នៅក្នុងប៉ុស្តិ៍ទល់ដែន ជាមួយពួកគេទៅ។
យើងរស់នៅជាមួយពួកនេះបណ្តើរ គិតបណ្តើរពីព្រោះគោលដៅយើង
មិនមែនចង់មករស់នៅត្រឹមទល់ដែននេះទេ គឺពួកយើងមានគោលបំណង
ចង់ទៅជួបពួកទូតបារាំង ឬអាមេរិកនៅឯទីក្រុងបាងកក ដើម្បីសុំសិទ្ធិជ្រកកោន
ជាជនភៀសខ្លួន ទៅរស់នៅឯស្រុកគេ
មិនមែនចង់មករស់នៅត្រឹមតែស្រុកសៀមនោះទេ។
រស់នៅជាយដែនបានប្រហែលជា១ខែកន្លះ
ពួកសៀមក្រហមរួមសហការជាមួយពួកខ្មែរក្រហម
បានវាយលុកបន្ទាយប៉ុស្តិ៍តំរួតជាយដែន ដែលខ្ញុំកំពង់តែរស់នៅនេះ
ទាំងកណ្តាលយប់អធ្រាត្រ ពួកវាបានបាញ់កាំភ្លើង B-40 ចូលក្នុងបន្ទាយខ្ញុំហើ
យមានបំណែកអេក្លាគ្រាប់ បានមកទម្លោះដៃខ្ញុំ
ដែលខ្ញុំបានដាក់គងនៅលើក្បាលអាចាន់ថា
ហើយអំបែងគ្រាប់នេះក៏បានទៅទម្លោះក្បាលមិត្តខ្ញុំនេះរាក់ៗទេ បើកុំតែវាមកប៉ះដៃខ្ញុំ
ប្រហែលជាធ្លុះក្បាលស្លាប់បាត់ទៅហើយ។ នេះក៏ដោយសារតែទេវតាជួយផងដែរ
នៅពេលព្រឹកព្រលឹម ពួកខ្មែរក្រហម-សៀមក្រហម ក៏បានដកថយទៅវិញអស់ទៅ
គេក៏បានយកឱត្តមភាគចក្រ មកដឹកពួកយើងទៅមន្ទីរពេទ្យ នៅឯទីក្រុងធំ
ដោយសារតែពេលនោះ នៅតំបន់ជាយដែន នៅពុំទាន់មានផ្លូវគមនាគមន៍ល្អ
ឡានអាចចូលទៅបាននៅឡើយទេ។ ការផ្តល់ស្បៀងអាហារនិងគ្រាប់រំសេវ
នៅតាមជាយដែន គឺសុទ្ធតែប្រើអេលីកូទាំងអស់ ដោយសារនៅពេលនោះ
ពុំទាន់មានផ្លូវគមនាគមន៍នៅតាមបណ្តោយព្រំដែននៅឡើយទេ។
ពួកយើងក៏មានចិត្តសប្បាយរីករាយណាស់
ដោយគិតថាពួកយើងនឹងលែងបានមករស់នៅតាមជុំរុំជាយដែននេះទៀតហើយ។
ចូលដេកពេទ្យបានតែ១ថ្ងៃ គេក៏ឲ្យពួកយើងចេញទៅរស់នៅក្នុងមន្ទីរឃុំឃាំងវិញ
ហើយយើងនឹកក្នុងចិត្តថា ទីនេះមានឡានបើកបរអ៊ូអររាល់ថ្ងៃ
យើងសង្ឃឹមថានឹងលួចរត់ចេញ ទៅទីក្រុងបាងកក
បានងាយស្រួលជាងរស់នៅតាមជាយដែន។
ពួកយើងជាជនមានសំណាងណាស់ ដែលបានមកដល់ដីថៃ ហើយថៃមិនសម្លាប់ចោ
លនោះ ក្រៅពីនោះសឹងតែ៨០% ត្រូវពួកថៃសម្លាប់ចោលស្ទើគ្មានសល់។
ពួកអ្នកដែលរត់មកដល់ស្រុកថៃក្រោយខ្ញុំ១អាទិត្យ មានគ្នា៦នាក់

សុទ្ធតែពួកអ្នកស្រុកលើ  និយាយរដើនៗ ត្រូវបានពួកថៃយកទៅសម្លាប់ចោលទាំងអស់
ឈ្មោះខ្មែរបានហូរទៅជាស្ទឹងហើយ។
យើងរស់នៅក្នុងគុកបានយូរបន្តិច ខំរៀនសរសេរ រៀននិយាយភាសាថៃ
បានចេះគួរសម អាចល្មមប្រើការបាន
គេក៏បន្ធូរបន្ថយអាចឲ្យយើងចេញទៅរកការងារធ្វើបាន រកលុយចាយបានខ្លះៗដែរ
ហើយនៅពេលយប់ យើងត្រូវវិលមកដេកនៅក្នុងគុកវិញ។លុះយូរបន្តិចមក
គេក៏កាន់តែទុកចិត្តយើងឡើងៗ យើងមិនបាច់មកដេកនៅក្នុងគុកវិញទេ
គឺឲ្យមកដេកនៅក្នុងបន្ទាយវិញ។ រស់នៅបាន៣-៤ខែ ពួកតំរួតថៃកាន់តែទុកចិត្តយើ
ងខ្លាំងឡើង គេក៏នាំយើងឲ្យមកធ្វើការ នៅតាមផ្ទះគេឯទីក្រុង
ហើយគេឲ្យលុយយើងតាមតម្លៃធម្មតា យើងខំសន្សំសំចៃលុយបាន១០០០បាត
ទុកធ្វើដំណើរមកទីក្រុងបា ងកក។ ថ្ងៃមួយយើងក៏បានរត់ចេញពីផ្ទះនាយតម្រួតថៃនោះ
មកទីក្រុងបាងកកតែម្តងយើងមិនសូវភ័យខ្លាចទេ ពីព្រោះអាងចេះនិយាយភាសាថៃ
បានគួរសម អាចដោះស្រាយបញ្ហាបានគួរសមដែរ ហើយអាចបន្លំខ្លួន
ធ្វើជាជនជាតិថៃបានទៀតផង។ នៅពេលមកដល់ទីក្រុងបាងកក ក៏ជិះឡានតាក់ស៊ី
មករកទូតអាមេរិក តែមើលទៅចូលមិនចុះ ដោយសារតម្រួតថៃយាមកាមច្រូងច្រាង
តឹងរឹងពេក។ នៅពេលនោះ ត្រូវចំថ្ងៃសុក្រស្ថានទូតទាំងអស់
នៅទីក្រុងបាងកកត្រូវបិតទ្វារអស់ យើងក៏ដើរទៅរកសណ្ឋាគារសំរាក១យប់សិន។
នៅព្រឹកឡើងយើងក៏បានដើរទៅរកស្ថានទូតបារាំងវិញម្តង
ដោយបានប្រើផែនទីសំរាប់ជួយរកផ្លូវផង
យើងលែងហ៊ានជិះឡានតាក់ស៊ីទៀតហើយពីព្រោះសាហ៊ុយលុយកាក់វាកាន់តែខើច។
នៅស្ថានទូតបារាំង ពុំមានតម្រួតយាមច្រូងច្រាងដូចទូតអាមេរិកទេ។
គេបានប្រាប់ឲ្យយើងទៅជួបស្រីបារាំងម្នាក់ ដែលជាអ្នកទទួលភ្ញៀវ
គាត់ស្មានតែពួកយើងជាជនជាតិថៃ មកសុំវីសាបោះត្រាលើប៉ាស្ព័រ
ទៅលេងស្រុកបារាំង។
គួរឲ្យអនិច្ចារខ្លួនណាស់នៅពេលនោះយើងនិយាយបារាំងមិនចេញសោះ
ភ្លេចអស់រលីងឈឹង រកនិយាយមិនចេញ មិននឹកស្មានថាខ្លួនឯង ដល់ថ្នាក់នេះសោះ
នេះហើយដោយសារតែការរស់នៅក្នុងរបបប៉ុលពតជាង២ឆ្នាំ ធ្វើឲ្យយើងភ្លេចអស់
សូម្បីតែតួអក្សរបារាំង១តួ ក៏មិនដែលឃើញផង ទំរាំនិយាយបានមួយម៉ាត់ៗ
ដូចកូនក្មេងទើបតែរៀនប្រកបតួអក្សរអញ្ចឹង។និយាយគ្នាជាមួយស្រីបារាំងនេះ
មិនទាន់បានដឹងរឿងគ្នាផង វាក៏ប្រាប់ថាថ្ងៃនេះជាថ្ងៃសុក្រ (ពេលថ្ងៃត្រង់)
ស្ថានទូតត្រូវបិតទ្វារហើយ បើមានការអីត្រូវត្រឡប់មកវិញនៅថ្ងៃច័ន្ទទៀត។
យើងក៏បានត្រឡប់មកដល់សណ្ឋាគារវិញ ទាំងអស់សង្ឃឹម
ដោយចង់ដាច់សាហ៊ុយទៀតផង ហើយត្រូវរង់ចាំ២-៣ថ្ងៃទៀតផង។
ឱអនិច្ចារខ្លួនណាស់នៅពេលនេះយើងនា
គ្នាដេកគិត ខំរិះរកពាក្យសំរាប់យកទៅនិយាយជាមួយគេ ខំសរសេរកត់ត្រាទុក
កុំឲ្យភ្លេច សំរាប់យកទៅនិយាយនៅថ្ងៃច័ន្ទ ដើម្បីកុំឲ្យបិបិកដូចថ្ងៃនេះទៀត។
យើងគិតមើលទៅត្រូវដេករង់ចាំអស់៣យប់ទៀត
យើងអាចមានលុយបង់ថ្លៃសណ្ឋាគារត្រឹមតែ២ថ្ងៃទៀតទេ គឺដល់ត្រឹមថ្ងៃអាទិត្យ

យើងនឹងត្រូវដេកនៅតាមចិញ្ចើមថ្នល់ហើយ ពី ព្រោះយើងបានគិតទុកថា
យើងមកទីក្រុងបាងកកតែ៣ថ្ងៃទេយ៉ាងយូរ នឹងបានសំរេចការហើយ។
ស្អែកឡើងព្រឹកថ្ងៃសៅរ៍
យើងបានដើរទៅរកសាលាមហាវិទ្យាល័យជូឡាឡុងកនពីព្រោះធ្លាប់ឮល្បីតាំងតែពីនៅ
ស្រុកខ្មែរមកម្លេះថា ជាមហាវិទ្យាល័យធំជាងគេនៅទីក្រុងបាងកកនេះ
ក្នុងគោលបំណងចង់ជួបពួកសាស្ត្រាចារ្យ
បារាំងអាមេរិកដែលបានមកបង្រៀននៅសាលានេះ
ដើម្បីនិយាយទាក់ទងពួកវាក្រែងគេអាណិតជួយយើងបានខ្លះ ដោយថ្ងៃនេះជាថ្ងៃសៅរ៍
នៅពេលយើងបានទៅដល់សាលានេះ មិនមានកូនសិស្សរៀនទេ
មានតែពួកកូនសិស្សមកលេងកីឡាតែប៉ុណ្ណោះ។
យើងក៏ចេះតែដើរផ្សងព្រេងនៅក្នុងសាលា ហើយក៏បានជួបបារាំងម្នាក់
ស្មានថាជាសាស្ត្រាចារ្យបង្រៀននៅសាលានេះ។ យើងខំនិយាយភាសាអង់គ្លេសដាក់វា
ស្មានតែគ្រូអាមេរិកកាំង តែក្រោយមកទើបដឹងថា វាជាអ្នកទេសចរណ៍បារាំងសោះ។
បន្ទាប់ពីនិយាយសាសងគ្នាបានមួយសន្ទុះធំ គាត់ក៏មានចិត្តអាណិតយើង
បានលូកដកលុយចេញពីហោប៉ៅទាំងអស់ ឲ្យ មកយើង បាន១០០បាតដែរ។
គាត់ប្រាប់យើងថា លុយគាត់ទុកលុយនៅឯសណ្ឋាគារឯណោះ
គាត់ក៏បានណាត់ជួបយើង នៅឯស្ថានទូតបារាំង នៅថ្ងៃច័ន្ទទៀតផងដែរ។
ពួកយើងសែនមហាត្រេកអរក្រៃពេក នឹងអំណោយដ៏សប្បុរសធម៌នេះ
ដែលមិនអាចកាត់ថ្លៃបាន ពីព្រោះយើងគិតថាយ៉ាងហោចណាស់
យើងអាចរស់បានរហូតដល់ថ្ងៃច័ន្ទទៀតដែរ
មិនសូវធ្វើឲ្យយើងព្រួយបារម្ភពេកដូចមុនទៀតទេ។
លុះដល់ព្រឹកថ្ងៃច័ន្ទ គេឲ្យទៅជួបស្ទីក្គិ៤បារាំងម្នាក់ ទទួលបន្ទុកខាងជនភៀសខ្លួន
យើងបាននិយាយជាមួយគេ សុំធ្វើជាជនភៀសខ្លួននយោបាយ
ហើយសុំគេទៅរស់នៅស្រុកបារាំង នៅពេលនោះគេបានប្រាប់យើងថា.....?
**សូមជួយសរសេរបន្តបញ្ចប់សាច់រឿងនេះផង**